ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី២ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី២ សម្រាប់ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-បទបង្ហាញពីសកម្មភាពសំខាន់ៗក្នុងការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

-បទបង្ហាញពីសកម្មភាពប្រយុទ្ធទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព (HACC)។

-បទបង្ហាញពីសកម្មភាពប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់អង្គការ KHANA។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត ហោ ប៊ុនឡេង** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

<u>ប្រធានបទទី១</u>: បទបង្ហាញពីកម្ពុជាឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅ៩០-៩០-៩០ ដោយ **លោកវេជ្ជបណ្ឌិត ឡាន វណ្ណសេង** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល ដោយលោកវេជ្ជបណ្ឌិតបានធ្វើការពន្យល់បកស្រាយនូវចំណុចនីមួយៗដូចខាងក្រោម៖

- ✓ ការរុករកអ្នកជំងឺត្រូវធ្វើឡើងនៅតាមសហគមន៍ ហើយត្រូវបញ្ជូនពួកគាត់ទៅរកសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ បន្ទាប់មកត្រូវបញ្ចូលទៅក្នុងសេវាសុខាភិបាល ដើម្បីទទួលបានថ្នាំប្រឆាំងទៅនឹងមេរោគអេដស៍ជាប់រហូត។
- ✓ ការឈានឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅ៩០-៩០-៩០ (ដែលមានន័យថា ៩០% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩០% នៃអ្នកដែលបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩០% នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយបន្ទុកមេរោគអេដស៍នៅក្នុងខ្លួន)។

- ✓ គិតត្រឹមឆ្នាំ២០១៧ ចំពោះ ៩០ ទី១យើងសម្រេចបាន៨៦% ៩០ ទី២យើងសម្រេចបានរហូតដល់៩៨% និង៩០ ទី៣យើងសម្រេចបាន៨០%។
- ✓ ការធ្លាក់ចុះនៃថវិកាជំនួយអាចប៉ះពាល់ទៅនឹងសកម្មភាពមួយចំនួនដែលកំពុងអនុវត្ត សម្រាប់រយៈពេល ៣ឆ្នាំ ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ថវិកាជំនួយពីមូលនិធិសកលមានចំនួន៤២លានដុល្លាអាមេរិក ហើយមួយចំនួនធំត្រូវប្រើប្រាស់សម្រាប់ទិញឱសថប្រឆាំងមេរោគអេដស៍ និងថវិកាបន្តិចបន្តួចសម្រាប់ការងារបង្ការ អប់រំផ្សព្វផ្សាយ។ ចំពោះថវិកាជាតិមានការកើនឡើង សម្រាប់ធ្វើបដិភាគទៅនឹងការទិញឱសថប្រឆាំងមេរោគអេដស៍។

**ប្រធានបទទី២៖** បទបង្ហាញពីសកម្មភាពប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព បង្ហាញជូនដោយ **លោក ទឹម ថវ៉ា** តំណាងអង្គការ HACC បានធ្វើការបកស្រាយដូចខាងក្រោម៖

- ✓ គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព ( HACC ) គឺជាបណ្តាញឱ្យអង្គការសង្គមស៊ីវិលដែលកំពុងអនុវត្តវិស័យសុខាភិបាល ដែលបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ជាវេទិកាសម្រាប់អង្គការដែលអនុវត្តកម្មវិធីអេដស៍មកជួបជុំគ្នាដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍នានា ហើយបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃនៅខែវិច្ឆិកា ឆ្នាំ២០០៤។
- ✓ តួនាទី និងបទពិសោធន៍របស់ HACC៖
    - ការសម្របសម្រួល និងសហប្រតិបត្តិការ
    - យុទ្ធនាការបង្កើនការយល់ដឹង
    - ការងារជាបណ្តាញ
    - ការស្វែងរកការគាំទ្រ
    - ពង្រឹងប្រព័ន្ធសុខាភិបាល
    - ពង្រឹងប្រព័ន្ធសហគមន៍
- ✓ ផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៨-២០២០ ផ្តោតលើគោលដៅបួនគឺ ពង្រឹងលេខាធិការដ្ឋាន ពង្រឹងអង្គការសមាជិកភាព ពង្រឹងគោលនយោបាយ ការសម្របសម្រួល និងស្វែងរកការគាំទ្រពីបរិយាកាសគាំទ្រ និងពង្រឹងអំណាចសហគមន៍។
- ✓ ថវិកាសម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ មានតែមួយប្រភពគឺមូលនិធិសកលចំនួនតែ៤១.៦លានដុល្លារអាមេរិកសម្រាប់កម្មវិធីអេដស៍។
- ✓ និន្នាការនៃអង្គការសមាជិកធ្វើការលើកម្មវិធីអេដស៍ មានការថយចុះមកនូវត្រឹមតែ៣៨អង្គការ ក្នុងឆ្នាំ២០១៨ ដែលកាលពីឆ្នាំ២០១៤ មានរហូតដល់១២៤អង្គការ។
- ✓ បញ្ហាប្រឈមសំខាន់ៗ៖
    - ថវិកាមានការថយចុះពីម្ចាស់ជំនួយ
    - ចំនួនអង្គការមានការថយចុះ

- មិនមានកម្មវិធីបង្ការ
- គុណភាពនៃការផ្តល់សេវានៅមានកំរិត
- មិនមានថវិកាសម្រាប់អនុវត្តកម្មវិធី
- ក្រុមគោលដៅមិនសូវមានការគាំទ្រ
- បញ្ហាក្នុងការផ្លាស់ប្តូរក្រុមគោលដៅពីអង្គការមួយទៅអង្គការមួយ
- យន្តការនៃការសម្របសម្រួលមានការចុះថយ ដោយសារមិនមានថវិកា
- មិនមានថវិកាសំរាប់បណ្តាញជនរងគ្រោះ
- មិនមានថវិកាសំរាប់ជួយដល់ស្ថាប័នពាក់ព័ន្ធ

ក្រោយបង្ហាញចប់ឯកឧត្តមប្រធានអង្គប្រជុំ បានចាប់អារម្មណ៍ទៅលើការថយចុះនៃចំនួនអង្គការស៊ីវិល ដែលមានការថយចុះមកនូវត្រឹមតែ៣៨អង្គការ ក្នុងឆ្នាំ២០១៨នេះ ដែលវានឹងធ្វើអោយមានការខ្វះចន្លោះក្នុងការអនុវត្តសកម្មភាព។

- តំណាងអង្គការ WNU : ធ្វើសកម្មភាពអប់រំដល់ស្រ្តីបំរើសេវាកម្សាន្ត បុរសស្រឡាញ់បុរស ក្រុមបំលែងភេទ ហើយបញ្ហាដែលជួបប្រទះគឺនៅពេលដែលស្ត្រីត្រូវគេចាប់យកទៅដាក់នៅមណ្ឌលព្រៃស្អ ដែលមានផ្ទុកមេរោគអេដស៍ត្រូវបានដាច់ថ្នាំ។ ពេលចេញមកវិញអ្នកខ្លះមិនហ៊ានទៅបើកថ្នាំដោយខ្លាចពេទ្យស្តីបន្ទោស ហើយអ្នកខ្លះទៅធ្វើតេស្តឈាមឡើងវិញ ដើម្បីបានថ្នាំប្រើសារជាថ្មី។
- ចំពោះបញ្ហានេះឯកឧត្តមប្រធានអង្គប្រជុំ បានមានប្រសាសន៍ថាគួរតែមានយន្តការដោះស្រាយជាប្រព័ន្ធ ដោយមានការចូលរួមពី NAA HACC PAC រាជធានីភ្នំពេញ ទើបដំណើរការបានជារៀងរហូត។
- តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ : សំណូមពរអោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អញ្ជើញប្រធានមណ្ឌលព្រៃស្អមកចូលរួមប្រជុំដើម្បីដោះស្រាយចំពោះបញ្ហានេះ។

<u>**ប្រធានបទទី៣**</u>៖ បទបង្ហាញពីសកម្មភាពប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់អង្គការ KHANA បង្ហាញជូនដោយ **លោក ព្រហ្ម ចាន់រិទ្ធ** តំណាងអង្គការ KHANA បានធ្វើការបកស្រាយដូចខាងក្រោម៖

- ✓ អង្គការ KHANA បានធ្វើសកម្មភាពទៅលើ២៣ រាជធានី ខេត្ត លើកលែងតែខេត្តកែប និងខេត្តស្វាយរៀង ដោយមានអង្គការជាដៃគូចំនួន១៩ ហើយបានទទួលថវិកាជំនួយពីមូលនិធិសកល និង USAID សម្រាប់ជំនួយបច្ចេកទេស។
- ✓ សម្រាប់ឆ្នាំ២០១៨ អង្គការ KHANA ធ្វើតែការងារបង្ការ មិនធ្វើលើការងារថែទាំទៀតទេ។
- ✓ ការរៀបចំ UIC code សម្រាប់ក្រុមប្រជាជនគន្លឹះបានចំនួន៨៧% ត្រឹមខែធ្នូឆ្នាំ២០១៧ (87% of KPs 60,593 out of 69,870 in coverage assigned with UIC)។
- ✓ ការងារជាអាទិភាពសម្រាប់ឆ្នាំ២០១៨៖
  - USAID បានផ្តល់មូលនិធិគាំទ្រសម្រាប់គម្រោងFlagship
  - ការបិទបញ្ចប់គំរូផ្តល់ជំនួយថ្មីរបស់មូលនិធិសកល
  - ការរៀបចំផ្ទេរកម្មវិធីទៅតាមសំណើផ្តល់ជំនួយមូលនិធិសកលសម្រាប់ឆ្នាំ២០១៨ ដែលអង្គការ KHANA ផ្តោតលើការបង្ការសម្រាប់តំបន់ភាគខាងត្បូង។
  - ជំនួយបច្ចេកទេសពីអង្គការ FHI 360 លើគម្រោង LINKAGES

- គំនិតថ្មីៈ ផ្តោតលើសកម្មភាពចុះអប់រំផ្ទាល់ និងការតាមរកករណីថ្មីតាមរយៈយន្តការបណ្តាញសង្គម ដែលជំរុញដោយមិត្តភ័ក្រ្ត ( peer-driven social networking mechanisms )
- ផ្តល់ជំនួយបច្ចេកទេសដល់គម្រោង Flagship ដែលគាំទ្របរិក្ខារសុខាភិបាល
- គាំទ្រការផ្ទេរសម្ភារ និងការអនុវត្តលើឯកសារដែលត្រូវធ្វើសមាហរណកម្មចូលក្នុងកិច្ចការពិគ្រោះយោបល់លើការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ដែលជាការងារប្រចាំថ្ងៃ។
- បង្រួមគំរូសេវាគ្លីនិកឈូកស ដើម្បីកាត់បន្ថយចំណាយ និងរក្សាសេវាសម្រាប់ក្រុមគោលដៅ
- បន្តគាំទ្រការគ្រប់គ្រងករណីសកម្ម B-IACM ចំនួនកន្លែង ក្នុងរាជធានី ខេត្តចំនួន៣
- បញ្ចប់ និងរៀបចំរបាយការណ៍សម្រាប់ FEW IBBS
- គាំទ្រការវិភាគទិន្នន័យ ការសរសេររបាយការណ៍ ការផ្សព្វផ្សាយ PWUD/PWID និងទំហំប៉ាន់ប្រមាណឆ្នាំ២០១៧។
- ការបិទបញ្ចប់គម្រោង HIV/AIDS Flagship។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំដូចតទៅៈ

✓ តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានធ្វើបទបង្ហាញពីកម្ពុជាឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅ៩០-៩០-៩០។

✓ HACC បានធ្វើបទបង្ហាញពីសកម្មភាពដែលបានធ្វើកន្លងមក និងកំពុងបន្តធ្វើ ដោយបង្ហាញពីកង្វល់នៃការថយចុះចំនួនអង្គការក្នុងឆ្នាំ២០១៨នេះ ដោយសារការកាត់បន្ថយជំនួយពីខាងក្រៅ។

✓ ចំពោះអង្គការ KHANA បានធ្វើសកម្មភាពគ្របដណ្តប់បានច្រើនហើយធ្វើតែលើក្រុមប្រជាជនគោលដៅប៉ុណ្ណោះ តែក៏ប្រឈមទៅនឹងការបាត់បង់ថវិកាជំនួយផងដែរ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង២០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ព័ន្ធៈ**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការ**

**វេជ្ជ.តែន គន្ធី**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

**អ្នកធ្វើរបាយការណ៍**